**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ........៨១២........អពដ

GENERAL DEPARTMENT OF TAXATION

L202502040156TD3887

ថ្ងៃសុក្រ ៨រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់លិខិតជូនដំណឹងស្តីពីការប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក-លោកស្រីជាអភិបាល ឬបណ្ណាធិការសហគ្រាស ឬកម្មសិទ្ធិករសហគ្រាស អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ ឱ្យបានជ្រាបថា ដើម្បីធានាភាពត្រឹមត្រូវនៃការបំពេញកាតព្វកិច្ចប្រកាសនិងបង់ពន្ធនិងផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យបានឆាប់រហ័ស ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីណាមួយក្នុងការប្រកាសនិងបង់ពន្ធ អគ្គនាយកដ្ឋានពន្ធដារនឹងជូនដំណឹងទៅសហគ្រាសស្តីពីការប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ (ដូចក្នុងឧបសម្ព័ន្ធទី១) និងភ្ជាប់ជាមួយតារាងឧបសម្ព័ន្ធលម្អិតអំពីប្រតិបត្តិការ (ដូចក្នុងឧបសម្ព័ន្ធទី២) ដែលបានរកឃើញដោយអគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារនឹងផ្ញើលិខិតជូនដំណឹងនេះ ជូនលោក-លោកស្រី ដល់ទីតាំងសហគ្រាសផ្ទាល់ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច ហើយលោក-លោកស្រី អាចធ្វើការឆ្លើយតបមករដ្ឋបាលសារពើពន្ធវិញ ដូចខាងក្រោម៖

- **ករណីយល់ស្របតាមលិខិតជូនដំណឹងនេះ៖** លោក-លោកស្រី មានរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ដើម្បីបង់ប្រាក់ពន្ធ និងពន្ធបន្ថែមនៅធនាគារពាណិជ្ជជាដៃគូដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតាមរយៈប្រព័ន្ធគ្រប់គ្រងការបង់ប្រាក់ពន្ធតាមអនឡាញ (e-Payment System) ដោយប្រើប្រាស់លេខបារកូដ ឬ QR Code ដែលមាននៅលើលិខិតជូនដំណឹងជាការស្រេច។ ក្រោយពេលបង់ប្រាក់ពន្ធ តាមលិខិតជូនដំណឹងនេះរួចរាល់ ប្រព័ន្ធនឹងកែតម្រូវប្រតិបត្តិការនៃការប្រកាសពន្ធដោយស្វ័យប្រវត្តិ ទៅក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម របស់លោក-លោកស្រី។
- **ករណីមិនយល់ស្របតាមលិខិតជូនដំណឹងនេះ៖** លោក-លោកស្រី មានរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ដើម្បីឆ្លើយតបជាលាយលក្ខណ៍អក្សរនូវការមិនយល់ស្រប ចំពោះចំណែកណាមួយ ឬទាំងស្រុងចំពោះការរកឃើញរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់ជាមួយឯកសារបញ្ជាក់ជាសក្ខីកម្មទៅដាក់នៅបញ្ជរទទួលឯកសារនៃរដ្ឋបាលសារពើពន្ធ ឬតាមរយៈកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)។
- **ករណីលោក-លោកស្រីខកខានពុំបានឆ្លើយតបក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ** បន្ទាប់ពីបានទទួលលិខិតជូនដំណឹង រដ្ឋបាលសារពើពន្ធនឹងចេញលិខិតជូនដំណឹងលើកទី២ (ដូចក្នុងឧបសម្ព័ន្ធទី៣)។ ក្នុងករណីដែលលោក-លោកស្រីនៅតែពុំបានបង់ប្រាក់ពន្ធ តាមការកំណត់នេះ ឬពុំបានឆ្លើយតបក្នុងរយៈពេលដែលបានកំណត់លើលិខិតជូនដំណឹងលើកទី២ នោះប្រាក់ពន្ធ នឹងត្រូវកត់ត្រាជាបំណុលពន្ធ និងជាកម្មវត្ថុនៃការចុះធ្វើសវនកម្មពន្ធដារ ឬមានវិធានការតឹងទារ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។



អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

L202502040156TD3887

*ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារសូមស្នើដល់ លោក-លោកស្រីសូមមានការប្រុងប្រយ័ត្ន និងពិនិត្យឱ្យបានច្បាស់លាស់ ចៀសវាងមានការក្លែងបន្លំឯកសារ ឬលិខិតរដ្ឋបាលនានា ដែលលិខិតទាំងអស់ត្រូវអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយមាន QR Code និងលេខបារកូដសម្គាល់ច្បាស់លាស់ ដែលលោក-លោកស្រី អាចត្រួតពិនិត្យភាពត្រឹមត្រូវនៃលិខិតជូនដំណឹងនេះ ឬលិខិតនានា តាមរយៈ**កម្មវិធី GDT Check & Track** ដោយជ្រើសរើសមុខងារ "**ត្រួតពិនិត្យឯកសារ**" រួចស្កេន QR Code ដែលមានលើលិខិតនោះ។*

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាអភិបាល ឬបណ្ណាធិការសហគ្រាស ឬកម្មសិទ្ធិករសហគ្រាស អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

*ទាញយកកម្មវិធី*
*GDT Check & Track*

*Telegram Channel*
***ព័ត៌មានពន្ធដារកម្ពុជា***

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គនាយកដ្ឋានពន្ធដារ**
នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
*លេខ .................. អពដ/ន/អជ*

GENERAL DEPARTMENT OF TAXATION

(១)

IEFL2025011700008

ថ្ងៃអង្គារ ៨ រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៥

# លិខិតជូនដំណឹង
# ស្តីពី
# ការដាក់លិខិតប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ

ឈ្មោះសហគ្រាស ៖ បុប្ផា XXXXXX
ជាអក្សរឡាតាំង ៖ Bopha XXXXXX
លេខអត្តសញ្ញាណកម្ម ៖ L001-100XXXXXX ស្ថិតក្រោមការគ្រប់គ្រង ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
សកម្មភាពអាជីវកម្ម ៖ ផលិតកេសជ្ជៈ
អាសយដ្ឋាន ៖ ផ្ទះលេខ ៨៦-៨៨ ផ្លូវ ព្រះនរោត្តម (៤១) ភូមិ ១១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

---

**កម្មវត្ថុ** ៖ ការស្នើសុំកែតម្រូវលើការដាក់លិខិតប្រកាសបង់ពន្ធដែលមិនបានប្រកាសបង់ពន្ធត្រឹមត្រូវ។
**យោង** ៖ - ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣
- សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ
- លទ្ធផលនៃការពិនិត្យនិងផ្ទៀងផ្ទាត់រកឃើញតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សូមជម្រាបលោក លោកស្រី នាយកសហគ្រាសជ្រាបថា សហគ្រាសរបស់លោក លោកស្រីមានភាពមិនប្រក្រតីក្នុងការដាក់លិខិតប្រកាសបង់ពន្ធនាពេលកន្លងមក តាមរយៈលទ្ធផលនៃការពិនិត្យនិងផ្ទៀងផ្ទាត់លើប្រតិបត្តិការរវាងសហគ្រាសនានា ជាមួយនឹងសហគ្រាសលោក លោកស្រី ដែលមានក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ប្រចាំខែមករា ឆ្នាំ២០២៤ ដល់ ខែកុម្ភៈ ឆ្នាំ២០២៤ ដូចមានបញ្ជាក់នៅក្នុងតារាងខាងក្រោម៖

| ល.រ | ខែ ឆ្នាំ | ប្រភេទពន្ធ | ទឹកប្រាក់ពន្ធ | ប្រាក់ពន្ធបន្ថែម | សរុប |
|---|---|---|---|---|---|
| 1 | 01/2024-02/2024 | ពន្ធលើប្រាក់បៀវត្ស | 1,177,500 ៛ | 117,750 ៛ | 1,295,250 ៛ |
| 2 | 01/2024-02/2024 | ពន្ធលើអត្ថប្រយោជន៍បន្ថែម | 1,000,000 ៛ | 100,000 ៛ | 1,100,000 ៛ |
| 3 | 01/2024-02/2024 | ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | 145,455 ៛ | 14,545 ៛ | 160,000 ៛ |
| 4 | 01/2024-02/2024 | ពន្ធកាត់ទុកលើសេវាកម្ម ១៥% | 150,000 ៛ | 15,000 ៛ | 165,000 ៛ |
| 5 | 01/2024-02/2024 | អាករលើតម្លៃបន្ថែម | 1,454,545 ៛ | 145,455 ៛ | 1,600,000 ៛ |
| 6 | 01/2024-02/2024 | អាករពិសេសលើទំនិញមួយចំនួន | 60,000 ៛ | 6,000 ៛ | 66,000 ៛ |
| 7 | 01/2024-02/2024 | អាករសម្រាប់បំភ្លឺសាធារណៈ | 80,000 ៛ | 8,000 ៛ | 88,000 ៛ |
| | | សរុប | 4,067,500 ៛ | 406,750 ៛ | 4,474,250 ៛ |

SAMPLE

( ១ )

IEFL2025011700008

លោក លោកស្រីមានរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយទទួលបានលិខិតជូនដំណឹងនេះ សម្រាប់ឆ្លើយតបជាលាយលក្ខណ៍អក្សរមកនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំវិញ នូវការបដិសេធចំណែកណាមួយ ឬទាំងស្រុងចំពោះការរកឃើញ ដោយត្រូវមានភ្ជាប់ជាមួយឯកសារបញ្ជាក់ជាភស្តុតាងផងដែរ។ ការមិនបានឆ្លើយតបក្នុងរយៈពេលនេះ ចាត់ទុកថាលោក លោកស្រីបានយល់ព្រមតាមការរកឃើញរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ហើយលោក លោកស្រីអាចបង់ប្រាក់ពន្ធ និងពន្ធបន្ថែម ដោយទទួលបានការលើកលែងការប្រាក់។ ក្នុងករណីដែលលោក លោកស្រីមិនបានឆ្លើយតបជាលាយលក្ខណ៍អក្សរ ឬមិនបានបង់ប្រាក់ពន្ធនិងពន្ធបន្ថែម ក្នុងរយៈពេលកំណត់ខាងលើនេះ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំនឹងចេញលិខិតជូនដំណឹងលើកទី២ ហើយលោក លោកស្រីនឹងមិនត្រូវទទួលបានការលើកលែងការប្រាក់ទៀតនោះទេ។ លើសពីនេះ ក្នុងករណីដែលលោក លោកស្រីមិនបានបង់ប្រាក់ពន្ធ និងពន្ធបន្ថែម និងការប្រាក់ក្នុងរយៈពេលកំណត់ក្នុងលិខិតជូនដំណឹងលើកទី២ នោះ ប្រាក់ពន្ធ និងពន្ធបន្ថែម និងការប្រាក់នឹងត្រូវបានកត់ត្រាជាបំណុលពន្ធ និងទទួលរងវិធានការទារ និងតឹងទារបំណុលពន្ធ និងជាកម្មវត្ថុនៃការចុះធ្វើសវនកម្មពន្ធដារ។

សូមជូនភ្ជាប់មកជាមួយនូវប្រតិបត្តិការលម្អិតដែលត្រូវបានពិនិត្យនិងផ្ទៀងផ្ទាត់រកឃើញក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារនៅក្នុងឧបសម្ព័ន្ធនៃលិខិតជូនដំណឹងនេះ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីនាយកសហគ្រាសប្រកាសបង់ពន្ធឱ្យបានឆាប់រហ័ស ដើម្បីជៀសវាងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំចុះធ្វើសវនកម្មដល់ទីកន្លែង ស្របតាមបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ។

សូមលោក លោកស្រីនាយកសហគ្រាស ទទួលនូវការរាប់អាន ពីខ្ញុំ

**ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ**

មន្ត្រីបញ្ចូលទិន្នន័យ៖ មន្ត្រី 3884 តេស្ត

អគ្គនាយកដ្ឋាន ពន្ធដារ

**សុខ តារា** 1

SAMPLE

# ឧបសម្ព័ន្ធទី២

IEFL2025011700008 (១)

**ឧបសម្ព័ន្ធ**
**ស្តីពី**
**ការប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ**

មូលដ្ឋានគិតពន្ធដែលសហគ្រាសប្រកាសនិងបង់មិនបានត្រឹមត្រូវ សម្រាប់អាករលើតម្លៃបន្ថែម និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលមានដូចខាងក្រោម៖

| ល.រ | កាលបរិច្ឆេទ | លេខវិក្កយបត្រ | លេខអ.ត.ប | ឈ្មោះសហគ្រាស | តម្លៃសរុបលើវិក្កយបត្រ | តម្លៃមិនរួមអតប | អតប 10% |
|---|---|---|---|---|---|---|---|
| 1 | 23-02-2024 | INV-0001256 | GC0000001 | អតិថិជនទូទៅ | 5,000,000 ៛ | 4,545,455 ៛ | 454,545 ៛ |
| 2 | 09-01-2024 | INV24-0012 | L001-100XXXXXX | ក្រុមហ៊ុន XXXXXX | 11,000,000 ៛ | 10,000,000 ៛ | 1,000,000 ៛ |

SAMPLE

IEFL2025011700008

# ឧបសម្ព័ន្ធ
# ស្តីពី
# ការប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ

មូលដ្ឋានគិតពន្ធដែលសហគ្រាសប្រកាសនិងបង់មិនបានត្រឹមត្រូវ សម្រាប់ពន្ធកាត់ទុកទូទៅមានដូចខាងក្រោមៈ

| ល.រ | កាលបរិច្ឆេទ | លេខវិក្កយបត្រ | ប្រភេទអ្នកទទួលប្រាក់ | ឈ្មោះអ្នកទទួលប្រាក់ | ប្រភេទប្រតិបត្តិការ | មូលដ្ឋានគិតពន្ធ | ពន្ធកាត់ទុក |
|---|---|---|---|---|---|---|---|
| 1 | 26-01-2024 | INV24-001254 | រូបវន្តបុគ្គល | ប្រាក់ រំចក | ពន្ធកាត់ទុកលើសេវាកម្ម ១៥% | 1,000,000 ៛ | 150,000 ៛ |

SAMPLE

IEFL2025011700008

# ឧបសម្ព័ន្ធ
# ស្ដីពី
# ការប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ

មូលដ្ឋានគិតពន្ធដែលសហគ្រាសប្រកាសនិងបង់មិនបានត្រឹមត្រូវ សម្រាប់ពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែមមានដូចខាងក្រោម៖

| ល.រ | ខែ-ឆ្នាំ | ឈ្មោះនិយោជិត | មុខតំណែង | ប្រភេទ | សហព័ទ្ធ | កូនក្នុងបន្ទុក | ប្រាក់បៀវត្សគោល | ពន្ធលើប្រាក់បៀវត្ស | ប្រាក់អត្ថប្រយោជន៍បន្ថែម | ពន្ធលើអត្ថប្រយោជន៍បន្ថែម |
|---|---|---|---|---|---|---|---|---|---|---|
| 1 | 02-2024 | មីឈែល ម៉ាហូ | | និវាសនជន | មាន | - | 12,000,000 ៛ | 1,177,500 ៛ | 5,000,000 ៛ | 1,000,000 ៛ |

SAMPLE

**ឧបសម្ព័ន្ធទី៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
*លេខ .................. អពដ/ន/អជ*

(២)

IEFL2025012100018

ថ្ងៃអង្គារ ៧ កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៥

# លិខិតជូនដំណឹង
## ស្តីពី
## ការដាក់លិខិតប្រកាសបង់ពន្ធមិនបានត្រឹមត្រូវ

ឈ្មោះសហគ្រាស ៖ បុប្ផា XXXXXX
ជាអក្សរឡាតាំង ៖ Bopha XXXXXX
លេខអត្តសញ្ញាណកម្ម ៖ L001-100XXXXXX ស្ថិតក្រោមការគ្រប់គ្រង ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
សកម្មភាពអាជីវកម្ម ៖ ផលិតកេសជ្ជៈ
អាសយដ្ឋាន ៖ ផ្ទះលេខ ៨៦-៨៨ ផ្លូវ ព្រះនរោត្តម (៤១) ភូមិ ១១ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

**កម្មវត្ថុ** ៖ ការស្នើសុំកែតម្រូវលើការដាក់លិខិតប្រកាសបង់ពន្ធដែលមិនបានប្រកាសបង់ពន្ធត្រឹមត្រូវ។
**យោង** ៖
- ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣
- សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ
- លទ្ធផលនៃការពិនិត្យនិងផ្ទៀងផ្ទាត់រកឃើញតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ
- លិខិតជូនដំណឹងលើកទី១ លេខបារកូដ IEFL2025011700008 ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៥ របស់ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សូមជម្រាបលោក លោកស្រី នាយកសហគ្រាសជ្រាបថា សហគ្រាសរបស់លោក លោកស្រីមានភាពមិនប្រក្រតីក្នុងការដាក់លិខិតប្រកាសបង់ពន្ធនាពេលកន្លងមក តាមរយៈលទ្ធផលនៃការពិនិត្យនិងផ្ទៀងផ្ទាត់លើប្រតិបត្តិការរវាងសហគ្រាសនានា ជាមួយនឹងសហគ្រាសលោក លោកស្រី ដែលមានក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ប្រចាំខែមករា ឆ្នាំ២០២៤ ដល់ ខែកុម្ភៈ ឆ្នាំ២០២៤ ដូចមានបញ្ជាក់នៅក្នុងតារាងខាងក្រោម៖

| ល.រ | ខែ ឆ្នាំ | ប្រភេទពន្ធ | ទឹកប្រាក់ពន្ធ | ប្រាក់ពន្ធបន្ថែម | ការប្រាក់ | សរុប |
|---|---|---|---|---|---|---|
| 1 | 01/2024-02/2024 | ពន្ធលើប្រាក់បៀវត្ស | 1,177,500 ៛ | 117,750 ៛ | 194,288 ៛ | 1,489,538 ៛ |
| 2 | 01/2024-02/2024 | ពន្ធលើអត្ថប្រយោជន៍បន្ថែម | 1,000,000 ៛ | 100,000 ៛ | 165,000 ៛ | 1,265,000 ៛ |
| 3 | 01/2024-02/2024 | ប្រាក់រំដោះពន្ធលើប្រាក់ចំណូល | 145,455 ៛ | 14,545 ៛ | 25,500 ៛ | 185,500 ៛ |
| 4 | 01/2024-02/2024 | ពន្ធកាត់ទុកលើសេវាកម្ម ១៥% | 150,000 ៛ | 15,000 ៛ | 27,000 ៛ | 192,000 ៛ |
| 5 | 01/2024-02/2024 | អាករលើតម្លៃបន្ថែម | 1,454,545 ៛ | 145,455 ៛ | 255,000 ៛ | 1,855,000 ៛ |
| 6 | 01/2024-02/2024 | អាករពិសេសលើទំនិញមួយចំនួន | 60,000 ៛ | 6,000 ៛ | 10,050 ៛ | 76,050 ៛ |
| 7 | 01/2024-02/2024 | អាករសម្រាប់បំភ្លឺសាធារណៈ | 80,000 ៛ | 8,000 ៛ | 13,500 ៛ | 101,500 ៛ |
| | | សរុប | 4,067,500 ៛ | 406,750 ៛ | 690,338 ៛ | 5,164,588 ៛ |

SAMPLE

IEFL2025012100018

លោក លោកស្រីមានរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយទទួលបានលិខិតជូនដំណឹងនេះ សម្រាប់ឆ្លើយតបជាលាយលក្ខណ៍អក្សរមកនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំវិញ នូវការបដិសេធចំណែកណាមួយ ឬទាំងស្រុងចំពោះការរកឃើញ ដោយត្រូវមានភ្ជាប់ជាមួយឯកសារបញ្ជាក់ជាភស្តុតាងផងដែរ។ ការមិនបានឆ្លើយតបក្នុងរយៈពេលនេះ ចាត់ទុកថាលោក លោកស្រីបានយល់ព្រមតាមការរកឃើញរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ហើយលោក លោកស្រីអាចបង់ប្រាក់ពន្ធ និងពន្ធបន្ថែម ដោយទទួលបានការលើកលែងការប្រាក់។ ក្នុងករណីដែលលោក លោកស្រីមិនបានឆ្លើយតបជាលាយលក្ខណ៍អក្សរ ឬមិនបានបង់ប្រាក់ពន្ធនិងពន្ធបន្ថែម ក្នុងរយៈពេលកំណត់ខាងលើនេះ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំនឹងចេញលិខិតជូនដំណឹងលើកទី២ ហើយលោក លោកស្រីនឹងមិនត្រូវទទួលបានការលើកលែងការប្រាក់ទៀតនោះទេ។ លើសពីនេះ ក្នុងករណីដែលលោក លោកស្រីមិនបានបង់ប្រាក់ពន្ធ និងពន្ធបន្ថែម និងការប្រាក់ក្នុងរយៈពេលកំណត់ក្នុងលិខិតជូនដំណឹងលើកទី២ នោះ ប្រាក់ពន្ធ និងពន្ធបន្ថែម និងការប្រាក់នឹងត្រូវបានកត់ត្រាជាបំណុលពន្ធ និងទទួលរងវិធានការទារ និងតឹងទារបំណុលពន្ធ និងជាកម្មវត្ថុនៃការចុះធ្វើសវនកម្មពន្ធដារ។

សូមជូនភ្ជាប់មកជាមួយនូវប្រតិបត្តិការលម្អិតដែលត្រូវបានពិនិត្យនិងផ្ទៀងផ្ទាត់រកឃើញក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារនៅក្នុងឧបសម្ព័ន្ធនៃលិខិតជូនដំណឹងនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីនាយកសហគ្រាសប្រកាសបង់ពន្ធឱ្យបានឆាប់រហ័ស ដើម្បីជៀសវាងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំចុះធ្វើសវនកម្មដល់ទីកន្លែង ស្របតាមបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ។

សូមលោក លោកស្រីនាយកសហគ្រាស ទទួលនូវការរាប់អានពីខ្ញុំ

**ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ**

មន្ត្រីបញ្ចូលទិន្នន័យ៖ មន្ត្រី 3884 តេស្ត

**សុខ តារា** 1

SAMPLE